# ជៀសវាងប្រើថ្នាំអង់ទីប្យូទិកសំរាប់គ្រុនផ្ដាសាយធម្មតា
# Clear of Antibiotic for Colds
# WUML
# 9/24/06

វេជ្ជបណ្ឌិតនៅសកលវិទ្យាល័យវ៉ាស៊ិងតោន ទីក្រុង St. Louis មានប្រសាសន៍ថា រដូវគ្រុនផ្ដាសាយជិតមកដល់ហើយ ហើយជាពេលដែលគួរជ្រាបថា ថ្នាំអង់ទីប្យូទិក ពុំអាច មានប្រសិទ្ធភាពនឹងបំបាត់រោគគ្រុនផ្ដាសាយធម្មតាបានឡើយ។ មិនត្រឹមតែប៉ុណ្ណោះ ការប្រើថ្នាំអង់ទូប្យូទិក ដោយពុំត្រឹមត្រូវ តាមវិធីប្រើ អាចនាំមកនូវផលវិបាកផ្សេងៗទៀតផង។

វេជ្ជបណ្ឌិត David Mellinger, ជានាយករងនិងអគ្គវេជ្ជបណ្ឌិតនៃសកលវិទ្យល័យនេះ មានប្រសាសន៍ថា ថ្នាំអង់ទីប្យូទិក គឺសំរាប់ប្រើបំបាត់រោគ ដែលបណ្ដាលមកពីមេរោគបាក់តេរី។ រីឯរោគគ្រុនផ្ដាសាយធម្មតាវិញ គឺបណ្ដាលមកពីមេរោគវ៉ៃរើស។ ដូច្នេះ ថ្នាំអង់ទីប្យូទិក ពុំអាចមានប្រសិទ្ធភាពទៅលើរោគដែលបណ្ដាលមកពីមេរោគវ៉ៃរើសបានឡើយ។

លោកមានប្រសាសន៍បន្ថែមទៀតថា ការប្រើថ្នាំអង់ទីប្យូទិកហួសកំរិត អាចបណ្ដាលឲ្យមេរោគបាក់តេរីសមនឹងថ្នាំនេះផង។ រាងកាយរបស់យើងមានមេរោគបាក់តេរីនៅជាប់នឹងខ្លួន ហើយប្រសិនបើវាប្រទះនឹងអង់ទិប្យូទិកជាញឹកញាប់ វាអាចមានកម្លាំងខ្លាំងប្រឆាំងនឹងថ្នាំនេះបាន។ បន្ទាប់មក មេរោគបាក់តេរីទាំងនោះ អាចរាតត្បាតរាងកាយបានយ៉ាងងាយស្រួលបំផុត។ ឯថ្នាំអង់ទីប្យូ ទិកនេះ គឺមានថ្នាំ ប៉េលិស៊ីលិន ជាដើម។

ថ្នាំ ប៉េលិស៊ីលិន ជាជំពូកថ្នាំអង់ទីប្យូទិកម្យ៉ាង ដែលសំរាប់សម្លាប់មេរោគបាក់តេរី ដែលមានក្នុងរយៈពេលមួយសត្តវត្សកន្លងមកនេះ។ ប៉ុន្តែ រយៈពេលបន្ទាប់មកទៀត មេរោគបាក់តេរីបានសមទៅនឹងថ្នាំ ប៉េលិស៊ីលិន។ ឥឡូវនេះ ថ្នាំប្រភេទនេះ សំរាប់ប្រើតែជាមួយមេរោគ Streptococcus ដែលជាមេរោគធ្វើឲ្យកើតរោគឈឺបំពងករ ឬ Strep Stroat និងរោគមួយជំពូកទៀតតែប៉ុណ្ណោះ។

វេជ្ជបណ្ឌិត David Mellinger, មានប្រសាសន៍ថា អ្នកដែលមានរោគគ្រុនផ្ដាសាយធម្មតា ពុំគួរសុំថ្នាំអង់ទីប្យូទិកពីគ្រូពេទ្យរបស់ខ្លួនឡើយ។ ជំនួសថ្នាំនេះ អ្នកនោះគួរទទួលទានទឹកនិងសំរាកឲ្យបានច្រើន, ហើយប្រហែលជាអាចលេបថ្នាំដែលទិញនៅតាមហាងលក់ថ្នាំ ដោយពុំបាច់មានវេជ្ជបញ្ញាតិបានផង។

ចំពោះពត៌មានបន្ថែម ស្ដីអំពីថ្នាំអង់ទីប្យូទិក អស់លោក-លោកស្រីអាចអានវ៉ិបសៃរបស់បណ្ឌិតសភាអាមេរិកាំងសំ រាប់គ្រូពេទ្យគ្រួសារ, American Academy of Family Physicians www.familydoctor.org ។

*អត្ថបទនេះដកស្រង់និងបកប្រែចេញពីសារពត៌មាន Healthfinder នៃ ក្រសួងសុខភាព និងមនុស្សធម៌ U.S. Department of Health and Human Services។ ដោយ មណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាព សហគមន៍ក្រុងឡូវែល។*

http://www.healthfinder.gov/news/newsstory.asp?docid=534520